**អង្គរបុរី**
**សម្លេងខ្មែរនៅបរទេស**

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ពុទ្ធភាសិតថា ការមិនមានរោគ ជាលាភដ៏ប្រសើរ ។

website: www.hoksavann.org
ថ្ងៃទី២៨ មករា ២០០៨



ពុទ្ធភាសិតថា ការនិនមានរោគជាលាភដ៏ប្រសើរនេះ ចេញមកពីបាលីថា អរោគ្យា បរមា លាភា ។ ពុទ្ធភាសិតនេះមានន័យថា ការមិនមានរោគជាលាភ ឬជាការបានដ៏ប្រសើរ ព្រោះការបានវត្ថុដទៃ ដូចជាការបានទ្រព្យសម្បត្តិ ការមានបញ្ញា ពុំអាចធ្វើចិត្តឲ្យរីករាយ ព្រោះពុំអាចប្រើប្រាស់វត្ថុទាំងនោះបាន ដោយហេតុមានជម្ងឺ ។ បើពុំមានរោគវិញ ទោះបីខ្សត់ខ្សោយទ្រព្យសម្បត្តិ គ្មានយសសក្តិអ្វីក៏ដោយ ក៏នៅតែសប្បាយចិត្ត ហើយមានលទ្ធភាពយកកម្លាំងកាយប្រាជ្ញាទៅប្រើប្រាស់ដើម្បីប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមបាន ។ ចំពោះការប្រតិបត្តិធម៌វិញ បើមានរោគពុំអាចប្រតិបត្តិធម៌ឲ្យបានពេញបរិបូណ៌ឡើយ ។ នៅសម័យពុទ្ធកាល ព្រះពុទ្ធក៏មានវេជ្ជបណ្ឌិតប្រចាំការសំរាប់ពិនិត្យព្រះសុខភាពរបស់ព្រះអង្គដែរ ។ ការមិនមានរោគបានសេចក្តីថា មនុស្សកើតមកតាំងពីក្មេងពុំសូវឈឺមានសុខភាពល្អ បើឈឺក៏ឈឺបន្តិចបន្តួចដោយការប្រែប្រួលរដូវត្រជាក់ក្តៅ ។ នៅក្នុងគិរីមានន្ទសូត្រពោលថា កាលណាមានរូបតែងមានរោគ មនុស្សកើតមកពុំឈឺសោះពុំមានឡើយ ។ ប៉ុន្តែការមិនមានរោគក្នុងពុទ្ធភាសិតនេះ សំដៅយកការមិនមានរោគប្រចាំកាយ គឺការឈឺជាប់ជានិច្ច ។

ព្រះពុទ្ធបានសំដែងក្នុងបរមត្ថអភិធម្មថា រូបកាយជារបស់មនុស្សសត្វជាអនត្តា ប្រែថាមិនមានជារបស់ខ្លួន ព្រោះជាធម្មជាតិកើតពីគ្រឿងផ្សំបីធាតុទឹកដីភ្លើងខ្យល់ មិនស្តាប់បង្គាប់ ប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិ គឺកើតចាស់ឈឺស្លាប់ ។ តាមបទវិគ្គហៈថា ធម្មជាតិណាកើតឡើងហើយវិនាសទៅវិញ ធម្មជាតិនោះហៅថារូប ។ រូបនេះលោកប្រៀបដូចដុំនៃពពុះទឹកដែលប៉ោងហើយបែកធ្លាយទៅវិញ ។ ទោះបីរូបប្រកបដោយធម៌អនត្តា

មិនមានជារបស់ខ្លួន ក៏ព្រះពុទ្ធបានបង្រៀនឲ្យថែរក្សាខ្លួនប្រាណឲ្យមានសុខភាពល្អដោយឲ្យមានអនាម័យវិធីការពារកុំឲ្យកើតរោគ ។ កាលណាមានរោគ គឺមានជម្ងឺ ព្រះពុទ្ធបានឲ្យប្រើថ្នាំព្យាបាលរោគ ដូចព្រះអង្គបានអនុញ្ញាតឲ្យព្រះសង្ឃប្រើថ្នាំក្នុងពេលមានអាពាធ ។ កាលណាជីវិតរស់នៅយូរមានសុខភាពល្អ ការប្រតិបត្តិធម៌គឺការបំពេញអំពើជាកុសលក៏បានយូរ ។ ប៉ុន្តែបើរស់នៅយូរ បែរជាប្រព្រឹត្តអំពើអាក្រក់ទៅវិញ ការរស់នៅយូរនោះគ្មានបានប្រយោជន៍អ្វីឡើយ ផ្ទុយទៅវិញការរស់នៅយូរសាងអំពើបាបកាន់តែច្រើនឡើង ។ កាលណាកាយមានជម្ងឺ ការប្រតិបត្តិធម៌ក៏មិនងាយធ្វើចិត្តឲ្យស្ងប់ឡើយ ដោយចិត្តជាប់នឹងការឈឺចុកចាប់ ព្រោះកាយនិងចិត្តមានទំនាក់ទំនងគ្នា ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មនុស្សសត្វដែលកើតរោគតិចច្រើនជាងគ្នា ដោយសារអំពើល្អអាក្រក់របស់ខ្លួន ដែលបានកសាងពីមុនមក ផ្សំគ្នានិងការថែទាំខ្លួនក្នុងបច្ចុប្បន្នផង ។

ផ្លូវអាណាចក្រ បានបង្កើតមន្ទីរពេទ្យកាន់តែច្រើនឡើង ហើយបុគ្គលិកពេទ្យក៏កាន់តែកើនឡើងដែរ ដើម្បីតម្រូវដល់អ្នកជម្ងឺដែលកើតមានកាន់តែច្រើនឡើង ។ មានជម្ងឺខ្លះពេទ្យមិនទាន់រកថ្នាំឃើញនៅឡើយ ដើម្បីសម្លាប់មេរោគនៃជម្ងឺទាំងនោះ ។ ជម្ងឺខ្លះកើតពីមនុស្សខ្លួនឯងបង្កើតឡើង ដូចជារោគកើតពីការផឹកស្រាការលេងស្រី ការជក់បារីការជក់គ្រឿងញៀនជាដើម ដែលព្រះពុទ្ធឲ្យមនុស្សវៀរចាក ព្រោះជាអំពើអបាយមុខនាំឲ្យកើតរោគ ។ មានជម្ងឺខ្លះពេទ្យអាចព្យាបាលឲ្យជា តែមានជម្ងឺខ្លះពេទ្យមិនអាចព្យាបាលឲ្យជាឡើយ មានជម្ងឺខ្លះត្រូវស្លាប់ ។ ជម្ងឺធ្ងន់ស្រាលតែបានកែមិនបានមានហេតុផលរបស់វា តាមច្បាប់កម្មផល ពុំមែនបណ្តាលមកពីព្រះជាម្ចាស់អង្គណាឡើយ ។ ជម្ងឺមួយប្រភេទដែលមិនអាចកែបានគឺជម្ងឺចាស់ជរា ព្រោះកាលណាចាស់ជរាទៀងតែស្លាប់ ដូចពាក្យថា គាត់ស្លាប់ដោយជរាពាធ បើនៅក្មេងកើតរោគស្លាប់ត្រូវពោលថា គាត់ស្លាប់ដោយរោគាពាធ ។ ដោយឃើញថា មនុស្សកើតមកត្រូវស្លាប់ទៅវិញ គួរឲ្យសង្វេគតក់ស្លុតនេះហើយ បានជាមនុស្សគួរលើកយកមកពិចារណា ហើយមិនគួរសាងអំពើបាប មានការបៀតបៀនគ្នាជាដើមឡើយ ។ ពុទ្ធសាសនិកជនខំប្រតិបត្តិធម៌ ដើម្បីឲ្យបានសម្រេចព្រះនិព្វានជាការរំលត់ទុក្ខ ព្រោះឃើញភ័យក្នុងការកើតចាស់ឈឺស្លាប់នេះឯង ។ សាសនាដទៃថា បើចង់ផុតទុក្ខត្រូវធ្វើព្រះត្រូវទៅរស់នៅជាមួយព្រះនៅស្ថានសួគ៌នៅស្ថានព្រហ្ម ។ ព្រះពុទ្ធសំដែងថា ការទៅស្ថានសួគ៌ឬចុះនរកដោយសារអំពើរបស់ខ្លួនពុំមែនដោយសារព្រះជាម្ចាស់អង្គណាឡើយ ។ មួយទៀត ស្ថានសួគ៌ស្ថានព្រហ្មពុំមែនជាទីរំលត់ទុក្ខឡើយ ព្រោះនៅក្នុងភពប្រកបដោយជាតិមានខន្ធ៥ ។ ព្រះពុទ្ធសំដែងក្នុងអរិយសច្ច៤ ទុក្ខសច្ចបានដល់ការមានខន្ធ៥ជាតួទុក្ខ ឯព្រះនិព្វានជាការរំលត់ខន្ធ៥ជាបរមសុខ ៕ល៚